ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៤.....សហវ.....

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ... ឆ្នាំ២០១១

# សារាចរណែនាំ
## ស្តីពី
## នីតិវិធីតម្កល់ និងដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

ក្នុងរយៈកាលកន្លងមក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពិនិត្យឃើញថា៖ ក្រសួង ស្ថាប័នមានការចុះកិច្ចសន្យាផ្សេងៗមានជាអាទិ៍ កិច្ចសន្យាលទ្ធកម្ម កិច្ចសន្យាវិនិយោគ កិច្ចសន្យាជួល កិច្ចសន្យាផ្សេងៗទៀតជាមួយក្រុមហ៊ុនឯកជន ដែលតាមរយៈនេះបានតម្រូវឱ្យភាគីឯកជនតម្កល់ប្រាក់កក់សម្រាប់ធានាការអនុវត្តកិច្ចសន្យា ។ ប្រាក់កក់ទាំងនោះ ត្រូវបានតម្កល់នៅតាមក្រសួង ស្ថាប័នជាប់កិច្ចសន្យា ឬនៅធនាគារពាណិជ្ជមួយចំនួន ។

ដោយពិនិត្យឃើញរូបភាពនៃការកក់ប្រាក់ធានានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំជូនរាជរដ្ឋាភិបាលដាក់ចេញអនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ និងជាបន្តបន្ទាប់មានសារាចរណែនាំ និងប្រកាស ដើម្បីកំណត់នីតិវិធីឱ្យអនុវត្តក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា។ បន្ទាប់ពីការចេញអនុក្រឹត្យ សារាចរណែនាំ និងប្រកាសជាបន្តបន្ទាប់ក្រសួង ស្ថាប័នមួយចំនួនបានអនុវត្ត ប៉ុន្តែទន្ទឹមនេះក៏នៅមានក្រសួង ស្ថាប័នដទៃទៀតនៅពុំទាន់បានអនុវត្តពេញលេញនៅឡើយ ដោយក្រសួង ស្ថាប័នជាប់កិច្ចសន្យាមួយចំនួននៅតែបន្តតម្កល់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាក្នុងគណនីរបស់ខ្លួនដដែល ។ ប្រការនេះមានផលអវិជ្ជមានជាច្រើនដូចជា ការពុំបានឆ្លុះបញ្ចាំងនូវតំលាភាពពិតប្រាកដ បេឡាជាតិពុំអាចមានលទ្ធភាពធ្វើការកៀងគរប្រមូលសាច់ប្រាក់ទាំងនេះយកមកធ្វើចរាចរបាន មិនធានាសុវត្ថិភាពដោយការតម្កល់នៅធនាគារពាណិជ្ជអាចជួបនូវហានិភ័យជាយថាហេតុ ។

អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម / ០៥០៨/ ០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ អនុក្រឹត្យលេខ ៨២អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ សារាចរណែនាំ និងប្រកាសនានាដែលបានកំណត់នីតិវិធីបង់ប្រាក់កក់ តាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ពីប្រភពប្រាក់កក់ ការរក្សាសុវត្ថិភាព

ក្នុងការតម្កល់ប្រាក់កក់ និងការផ្តល់ការជឿទុកចិត្តរឹងមាំបន្ថែមទៀតដល់ភាគីឯកជន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ ៖

១.- ប្រាក់តម្កល់នោះទោះជារូបភាពជាប្រាក់កក់ ប្រាក់ធានា ឬជារូបភាពផ្សេងៗទៀត ដែលដាក់តម្កល់សម្រាប់ធានាការអនុវត្តកិច្ចសន្យានានា មានជាអាទិ៍ ៖ កិច្ចសន្យាសម្បទានដីសម្រាប់វិស័យកសិកម្ម និងទេសចរណ៍ កិច្ចសន្យាសម្បទានរុករក និងធ្វើអាជីវកម្មធនធានរ៉ែ កិច្ចសន្យាសម្បទានទាក់ទងនឹងសំណង់ហេដ្ឋារចនាសម្ព័ន្ធ កិច្ចសន្យាផ្តល់សេវាសាធារណៈ ឬទទួលសេវាសាធារណៈ កិច្ចសន្យាវិនិយោគ កិច្ចសន្យាជួល កិច្ចសន្យាទិញ ឬលក់ទំនិញ និងកិច្ចសន្យាផ្សេងៗទៀត រួមទាំងសម្រាប់ការចេញអាជ្ញាប័ណ្ណ ឬការធានានានា ចាប់ពីពេលនេះតទៅត្រូវកំណត់ថា "ប្រាក់កក់" នៅក្រោមសារាចរនេះ ដោយមិនគិតពីឈ្មោះដែលបានប្រើប្រាស់សម្រាប់ការដាក់តម្កល់នោះឡើយ ។

២.- រាល់ប្រាក់កក់ទាំងអស់ត្រូវកំណត់ឱ្យបង់ចូលក្នុងគណនីទោលរតនាគារ របស់អគ្គនាយកដ្ឋានរតនាគារជាតិ ក្នុងរយៈពេលយ៉ាងយូរពី ៣០ថ្ងៃ ក្រោយកិច្ចសន្យាចូលជាធរមាន ឬតាមខ្លឹមសារដែលមានចែងក្នុងកិច្ចសន្យា ។

៣.- ប្រាក់កក់ត្រូវធានាផ្តល់ប្រគល់ជូន ភាគីកិច្ចសន្យា ឬអ្នកកក់ប្រាក់ ឬអ្នកទទួលអាជ្ញាប័ណ្ណវិញនៅពេលដល់កាលកំណត់នៃការដកប្រាក់កក់ ឬតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យា ។

៤.- ចំពោះប្រាក់កក់ ដែលកំពុងតម្កល់នៅគណនីរបស់ក្រសួង ស្ថាប័នសាមី ត្រូវចាត់ចែងផ្ទេរចូលក្នុងគណនីទោលរតនាគារ របស់អគ្គនាយកដ្ឋានរតនាគារជាតិ ជាការប្រញាប់ ។

៥.- គណនីទោលរតនាគាររបស់អគ្គនាយកដ្ឋានរតនាគារជាតិ សម្រាប់ប្រាក់រៀលមានលេខ 0000000 ១១១១ និងសម្រាប់ប្រាក់រូបិយវត្ថុដុល្លារអាមេរិកមានលេខ 00000000 ១៣៣៣ នៅធនាគារជាតិនៃកម្ពុជា ។

៦.- ភាគីកិច្ចសន្យា អ្នកកក់ប្រាក់ ឬអ្នកទទួលអាជ្ញាប័ណ្ណ ត្រូវប្រគល់ប័ណ្ណបង់ប្រាក់កក់ ដែលចេញដោយធនាគារជាតិនៃកម្ពុជា ជូនទៅភាគីក្រសួង ស្ថាប័ន ជាប់កិច្ចសន្យាចំនួនមួយច្បាប់ និងជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាក្រសួងមានសមត្ថកិច្ចផ្តល់ការយល់ព្រមលើកិច្ចសន្យាចំនួនមួយច្បាប់ ដើម្បីត្រួតពិនិត្យ និងតាមដានការអនុវត្តកិច្ចសន្យា ។

៧.- ការដកប្រាក់កក់ត្រូវអនុវត្តតាមបែបបទដូចខាងក្រោមនេះ ៖

ក្រសួង ស្ថាប័នជាប់កិច្ចសន្យាត្រូវពិនិត្យ និងបញ្ជូនសំណើសុំដកប្រាក់កក់របស់ភាគីកិច្ចសន្យា អ្នកកក់ប្រាក់ ឬអ្នកទទួលអាជ្ញាប័ណ្ណ ដោយភ្ជាប់មកជាមួយនូវ កិច្ចសន្យា ប័ណ្ណបង់ប្រាក់កក់ និងឯកសារពាក់ព័ន្ធបញ្ជាក់ពីការបានបំពេញលក្ខខណ្ឌក្នុងកិច្ចសន្យា កំណត់ហេតុប្រគល់ទទួលសំណង់ ឬសម្ភារៈ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ) ក្នុងរយៈពេល៥ថ្ងៃ ។ ក្នុងករណីដែលក្រសួង ស្ថាប័នជាប់កិច្ចសន្យាពិនិត្យឃើញថាមិន

ទាន់ដល់កាលវសាន ឬក៏ភាគីកិច្ចសន្យា អ្នកកក់ប្រាក់ ឬអ្នកទទួលអាជ្ញាប័ណ្ណ មិនទាន់បានបំពេញល័ក្ខខ័ណ្ឌ ដែលអាចដកប្រាក់កក់វិញបាន ឬមិនបានភ្ជាប់ឯកសារពាក់ព័ន្ធបានគ្រប់គ្រាន់ នោះក្រសួង ស្ថាប័នជាប់កិច្ចសន្យាត្រូវបញ្ជូនសំណើត្រឡប់ទៅភាគីឯកជនវិញជាបន្ទាន់ ។

ក្នុងរយៈពេល ៣ ថ្ងៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( អគ្គនាយកដ្ឋានរតនាគារជាតិ ) ត្រូវពិនិត្យលើសំណើសុំដកប្រាក់កក់ បើមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ត្រូវរៀបចំមូលប្បទានប័ត្រដកប្រាក់កក់ជូនភាគីឯកជន ឬឆ្លើយតបជាបន្ទាន់ទៅសាមីក្រសួង ស្ថាប័ន ជាប់កិច្ចសន្យាវិញក្នុងករណីដែលពិនិត្យឃើញថា ភាគីឯកជនពុំមានឯកសារគតិយុត្តិគ្រប់គ្រាន់ ឬមិនទាន់បានបំពេញតាមល័ក្ខខ័ណ្ឌស្តីពីការដកប្រាក់កក់បានត្រឹមត្រូវនៅឡើយ ។

៨.- ដោយឡែកនីតិវិធី និងទំរង់បែបបទកក់ប្រាក់ធានាការដេញថ្លៃ និងកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាលទ្ធកម្ម ត្រូវអនុវត្តតាមវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដូចមានចែងក្នុងសៀវភៅលទ្ធកម្ម ។

៩.- ក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវទទួលខុសត្រូវអនុវត្តនីតិវិធីតម្កល់ និងដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាឱ្យបានរ៉ឹងម៉ាំ ជៀសវាងដាច់ខាតការបង្កការលំបាកធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ និងសិទ្ធិការម្ចាស់របស់ ភាគីកិច្ចសន្យា អ្នកកក់ប្រាក់ ឬអ្នកទទួលអាជ្ញាប័ណ្ណ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមការណែនាំស្តីពីនីតិវិធីតម្កល់ និងដកប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាខាងលើនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>ចម្លងជូន:</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ឯកសារ